## ៨-១ បុណ្យប្រពៃណី

### ៨-១-១ ពិធី ចំរើនបរិត្ត

*កិច្ចចំរើនបរិត្ត ដែលអ្នកផងហៅថា សូត្រមន្តនោះ ពុទ្ធសាសនិកជន តែងធ្វើតាមពេល ត្រូវការ ឬ ក៏ដើម្បីបានសេចក្តីសុខចំរើនសិរីសួស្តី ដូចជាសូត្រមន្តឡើងផ្ទះថ្មីឬសូត្រ មន្តពេលរៀបអាពាហ៍ពិពាហ៍ជាដើម។ ដើម្បីសូត្រមន្តត្រូវ ៖*

*១-និមន្តព្រះសង្ឃ ទុកជាមុន (៥)*

*២-រៀបចំផ្ទះសម្បែងឬទីកន្លែងដែលត្រូវសូត្រឲ្យមានរបៀបរៀបរយ។ បើសូត្រនៅផ្ទះត្រូវតាំងអាសនៈនៃព្រះពុទ្ធរូប ដោយគ្រឿងសក្ការៈបូជា មានថូផ្កា ជាដើម មានផ្តិលទឹកព្រះបរិត្តដែលមានគ្រឿងអប់ឬផ្កា ដ៏មានក្លិនក្រអូបក្នុងនោះ សំរាប់ព្រះសង្ឃបាចទឹក ទៅលើពុទ្ធបរិស័ទទាំងឡាយ ។*

*៣-បន្ទាប់ពីចាត់ចែងភេសជ្ជៈប្រគេនព្រះសង្ឃ ឧបាសកជាប្រធានក្នុងពិធីបុណ្យ គប្បីផ្តើមអុជទៀនធូប នៅទីទាំងពួង ដែលគួរអុជ មានអាសនៈតាំងព្រះពុទ្ធរូប ជាដើម ហើយផ្តើមសូត្រនមស្សការព្រះរតនត្រ័យ។ ឧបាសកទាំងពួងគប្បីសូត្រ ជាមួយគ្នា ដោយ បញ្ចេញសំឡេង ។*

*៤-បន្ទាប់ពីនមស្សការ ព្រះរតនត្រ័យ រួចហើយ មានសមាទានសីល៥ ។*

*៥-បន្ទាប់ពីសមាទានសីលរួចហើយឧបាសកម្នាក់ អារាធនាព្រះសង្ឃសូត្រព្រះបរិត្ត ជាពាក្យបាលី ថា៖*

**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ**

**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ**

**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**

<u>ពន្យល់ន័យ</u>

សូមព្រះករុណាទាំងឡាយចំរើន នូវព្រះបរិត្ត ជាជ័យមង្គល ដើម្បីទឹង ការពារ បញ្ចៀសនូវវិបត្តិគឺសេចក្តី អន្តរាយទាំងពួង ដើម្បីឲ្យបានសម្រេចនូវ សម្បត្តិគ្រប់យ៉ាង ដើម្បី -**ញុំាងទុក្ខ** -**ញុំាង ភ័យ** -**ញុំាង រោគ** ទាំងអស់ ឲ្យវិនាសបាត់ទៅ ។

៦-បន្ទាប់ពីនេះទៅ ព្រះសង្ឃ លោកចាប់សូត្រព្រះបរិត្ត ,

៧-លុះចប់កិច្ចចំរើនព្រះបរិត្តហើយ អ្នកម្ចាស់ទានគប្បីបង្អោនទេយ្យទានទៅ

ប្រគេនព្រះសង្ឃ ,

៨-លុះប្រគេនទេយ្យទាននិងបរិក្ខារណាចតុប្បច្ច័យហើយ ព្រះសង្ឃ លោកសូត្រ

អនុមោទនា។

ចប់អនុមោទនាហើយឧបាសក សូត្រ យំ កិញ្ចិ... ឧទ្ទិសផល ជាកិច្ចបញ្ចប់បុណ្យ ៕

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។